**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ២០៤/១៤ ក.អ.ជ.ប្រក

ថ្ងៃ ច័ន្ទ ១ កើត ខែភទ្របទ ឆ្នាំមមី ព.ស. ២៥៥៨
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា គ.ស. ២០១៤

# ប្រកាស
## ស្តីពី
## ការតែងតាំងសមាសភាពលេខាធិការដ្ឋានរបស់គណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្ម អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងប្រកាសលេខ ១៤២/១៤ ក.អ.ជ.ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការត្រួតពិនិត្យយានយន្តដឹកលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំដែលបើកបរលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងប្រកាសលេខ ១៩៩/១៤ ក.អ.ជ/ប្រ.ក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

## **សម្រេច**

**ប្រការ១.-** តែងតាំងសមាសភាពលេខាធិការដ្ឋានរបស់គណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម÷

| | | | | | |
|---|---|---|---|---|---|
| ១. | លោក | **ខ៉ា** | **ម៉ិនណាក់** | អនុប្រធាននាយកដ្ឋាន | ប្រធាន |
| ២. | លោក | **ប៊ួយ** | **គីមស្រ៊ាង** | អនុប្រធាននាយកដ្ឋាន | អនុប្រធាន |
| ៣. | លោក | **គីម** | **ផល្លី** | ប្រធានការិយាល័យ | សមាជិក |
| ៤. | លោក | **ឆុក** | **បញ្ញា** | មន្ត្រី | សមាជិក |
| ៥. | កញ្ញា | **ទ័ន** | **សិដ្ឋា** | មន្ត្រី | ជាសមាជិក |

**ប្រការ២.-** លេខាធិការដ្ឋានរបស់គណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទ មានភារកិច្ចដូចខាងក្រោម÷

- ទុកដាក់ឯកសារ និងទិន្នន័យគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងការងារត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើផ្លូវជនបទ
- រៀបចំ និងព្រាងឯកសារ និងលិខិតស្នាមរដ្ឋបាលរបស់គណៈកម្មាធិការ
- រៀបចំកិច្ចប្រជុំ និងព្រាងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលគណៈកម្មាធិការប្រគល់ជូន។

**ប្រការ ៣.-** សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

<u>**កន្លែងទទួល**</u>

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
- *មន្ទីរពាក់ព័ន្ធ*
  *"ដើម្បីជូនជ្រាប"*
- *ដូចប្រការ ១, ២ និងប្រការ ៤*
  *"ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

ក្រសួងអភិវឌ្ឍន៍ជនបទ

**ជា សុផារ៉ា**